ព័ត៌មានសហគមន៍នេសាទនៅតំបន់ឆ្នេរ

# សហគមន៍នេសាទត្រពាំងសង្កែ ខេត្តកំពត (២០១៧)

## ស្ថានភាពទូទៅ

សហគមន៍នេសាទត្រពាំងសង្កែមានទីតាំងស្ថិតនៅភូមិត្រពាំងសង្កែ ភូមិកំពង់កេស និងភូមិត្រពាំងធំ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ សហគមន៍នេសាទនេះមានផ្ទៃដីទំហំ ៣៣៧ហិកតា មានសមាជិក២.០២៧នាក់ (ស្រី១.០២៩នាក់) នៅឆ្នាំ២០០៩ និង ៧៥៨នាក់ (ស្រី៣៦៩នាក់) នៅឆ្នាំ២០១៧ និងមានសមាជិកគណៈកម្មការសហគមន៍នេសាទចំនួន ០៩នាក់ (ស្រី០៣នាក់)។ មកដល់ឆ្នាំ២០១៧ សហគមន៍បានធ្វើបច្ចុប្បន្នភាពឯកសារ និងផែនទីដោយបែងចែកជា៣តំបន់ដូចជា កន្លែងនេសាទសហគមន៍ចំនួន៤១៥ហិកតា តំបន់ការពារព្រៃកោងកាងចំនួន០,៧ហិកតា និងកន្លែងទេសចរណ៍ចំនួន០,៨១ហិកតា។



**កាលបរិច្ឆេទបង្កើតសហគមន៍ ៖** ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩

**ការចុះបញ្ជី៖** បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១

### ការគាំទ្រពីអ្នកពាក់ព័ន្ធ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត
- ខណ្ឌរដ្ឋបាលជលផលខេត្តកំពត
- មន្ទីរបរិស្ថានខេត្តកំពត
- មន្ទីរទេសចរណ៍ខេត្តកំពត
- អាជ្ញាធរមូលដ្ឋាន

### ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល

- សហភាពអឺរ៉ុប
- អង្គការកសាងសម្លេងសហគមន៍
- មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីកម្ពុជា
- អង្គការក្រុមការងារពង្រឹងនិងអភិវឌ្ឍន៍សហគមន៍
- អង្គការអាក់សិនអេតកម្ពុជា
- អង្គការភ្លែនអន្តរជាតិ
- អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
- កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់
- អង្គការហ្វ៊ររ៉ុម ស៊ីដ

### ព័ត៌មានទំនាក់ទំនង

**ទូរស័ព្ទ៖** (+៨៥៥) ៩៦ ២៤៣ ០៨០
(+៨៥៥) ៧១ ៦៤៤ ៤៨៧៤

**ទំព័រហ្វេសប៊ុក៖** https://bit.ly/3EWj4s2

**អាសយដ្ឋាន៖** ភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។

**ឯកសារយោង៖**

- លក្ខន្តិកៈសហគមន៍នេសាទត្រពាំងសង្កែ
- បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រពាំងសង្កែ
- ផែនទីសហគមន៍នេសាទត្រពាំងសង្កែ
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទត្រពាំងសង្កែ
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងសង្កែ
- ប្រកាសលេខ១២៣ ស្តីពីការចុះបញ្ជីសហគមន៍នេសាទ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១

## មុខរបរចិញ្ចឹមជីវិត

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមាន៖

- ធ្វើនេសាទនិងធ្វើស្រែ
- ធ្វើវារីវប្បកម្មចំនួន០១គ្រួសារ
- ជាងផ្ទះចំនួន០៧គ្រួសារ
- ធ្វើសិប្បកម្មចំនួន០១គ្រួសារ
- ធ្វើផ្អកចំនួន៣០គ្រួសារ
- ធ្វើបង្គាក្រៀមចំនួន០៣គ្រួសារ។

## ជនជាតិ និងសាសនា

**ជនជាតិ៖** ខ្មែរ៤៧៣នាក់ និងខ្មែរឥស្លាម២៨៥នាក់

**សាសនា៖** សាសនាព្រះពុទ្ធនិងសាសនាកាតូលិក៦២ភាគរយ និងសាសនាឥស្លាម៣៨ភាគរយ។

## ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍៖ ៧៥៨នាក់ (ស្រី៣៦៩នាក់)

### អ្នកនេសាទ

ចំនួនអ្នកនេសាទជាសមាជិកសហគមន៍សរុប៖ ៥៥២នាក់ (ស្រី២៦៩នាក់)

ចំនួនអ្នកនេសាទមិនមែនជាសមាជិកសហគមន៍ដែលរស់នៅក្នុងសហគមន៍សរុប៖ ១.០២៣នាក់ (ស្រី៣៣៥នាក់)

ចំនួនអ្នកនេសាទដែលមកពីខាងក្រៅសហគមន៍សរុប៖ ១៧០នាក់ (ស្រី៣១នាក់)



## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដោយអនុលោមតាមប្រការ២៣នៃប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ ការនេសាទ និងកសិកម្ម លក្ខណៈនៃដែននេសាទ សកម្មភាពពាក់ព័ន្ធនឹងការ នេសាទ និងបញ្ហាដែលកើតមាននៅក្នុងសហគមន៍។ សហគមន៍នេសាទត្រពាំងសង្កែបានរៀបចំផែនការ៥ឆ្នាំ ដោយផ្តោតទៅលើការបង្កើនជីវភាពសហគមន៍ តាមរយៈសហគ្រប់គ្រង ការប្រើប្រាស់ធនធានជលផល និងធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌។ តាមរយៈទស្សនៈវិស័យរបស់សហគមន៍ សហគមន៍នេះក៏បានរៀបចំផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ (២០១៧-២០២១) ផងដែរ។

សហគមន៍នេសាទត្រពាំងសង្កែ បានរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិមានទំហំ០,៨១ហិកតាសម្រាប់ជាកន្លែងគ្រប់គ្រងព្រៃកោងកាង។ សហគមន៍ទេសចរណ៍ធម្មជាតិមិនត្រឹមតែដើរតួនាទីសំខាន់សម្រាប់បង្កើនជីវភាពរបស់សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមចំណែកក្នុងការបង្កើន និងស្តារធនធានព្រៃកោងកាងផងដែរ។ សហគមន៍ក៏បានរៀបចំផែនការបង្កើនបែរចិញ្ចឹមត្រីឆ្លង់ និងត្រីតុកកែ។

**ផែនការថវិកា៖** នៅក្នុងផែនការថវិកា សហគមន៍នេសាទត្រពាំងសង្កែមិនទាន់មានស្វ័យភាពថវិកានៅឡើយ ដោយសារត្រូវនៅពឹងផ្អែកលើប្រភពថវិកាមកពីភាគទានរបស់សមាជិកសហគមន៍ អំណោយពីសប្បុរសជន ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងថវិកាអភិវឌ្ឍន៍ឃុំ។

## តំបន់ការពារ និងកន្លែងគ្រប់គ្រងជលផល

មិនមានព័ត៌មាន

## កន្លែងគ្រប់គ្រងស្មៅសមុទ្រ និងព្រៃកោងកាងរបស់សហគមន៍នេសាទ

សក្តានុពលដែលសហគមន៍មើលឃើញអាចបង្កើតតំបន់គ្រប់គ្រងបានគឺស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍ ដែលបានបែងចែកជា២តំបន់ គឺតំបន់គ្រប់គ្រងស្មៅសមុទ្រទំហំ៤០ហិកតា និងតំបន់គ្រប់គ្រងព្រៃកោងកាងទំហំ៥៧ហិកតា។



## ធនធានជលផល

**មច្ឆជាតិ៖** ត្រី២៦ប្រភេទ និងវារីសត្វ២៣ប្រភេទ
**ផលនេសាទ៖** ៨.១១៧គីឡូក្រាម/គ្រួសារ/ឆ្នាំ។

## បញ្ហាប្រឈម

- ការទន្ទ្រានកាន់កាប់យកដីធ្លី
- ការកាប់បំផ្លាញព្រៃកោងកាង
- ការចាក់លុបឆ្នេរសមុទ្រ
- បទល្មើសនេសាទ

ផលិតដោយ

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia

actionaid

ជំនួយរបស់សហភាពអឺរ៉ុប

សហភាពអឺរ៉ុប

ឯកសារនេះរចនាដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) សហការជាមួយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងអង្គការអាកសិនអេតដោយគាំទ្រថវិកាពីសហភាពអឺរ៉ុប។ទិន្នន័យនិងព័ត៌មាននៅលើផ្ទាំងព័ត៌មានទិន្នន័យសហគមន៍នេសាទនៅតំបន់ឆ្នេរដកស្រង់ចេញពីឯកសារយោងដែលមានស្រាប់ និងមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។